Disability Rights California

ប្រព័ន្ធការពារ និងតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា
លេខទូរស័ព្ទហៅមិនអស់ប្រាក់ (800) 776-5746

# ការទទួលបាន បច្ចេកវិជ្ជាជំនួយតាមរយៈនិយោជក

*ខែតុលា ឆ្នាំ 2015 ឯកសារបោះពុម្ពផ្សាយ លេខ 5580.06 - Cambodian*

## 1. តើអ្វីគឺជាបច្ចេកវិជ្ជាជំនួយ?

ពាក្យថា "បច្ចេកវិជ្ជាជំនួយ" ("assistive technology") មានន័យថាជាបច្ចេកវិជ្ជាដែលគេយកវាទៅប្រើ ជាមួយនឹងឧបករណ៍បច្ចេកវិជ្ជាជំនួយ ឬក្នុងសេវាកម្មបច្ចេកវិជ្ជាជំនួយ ដើម្បី បង្កើន រក្សាបាន ឬកែលំអសមត្ថភាពចលនារាងកាយរបស់ជនដែលមាន ពិការភាពជាប់នឹងខ្លួន ។ 29 ក្រមសហរដ្ឋអាមេរិក (U.S.C., United States Code) វគ្គទី 3002(3)(4)(5)

## 2. តើមានច្បាប់អ្វីអនុញ្ញាតឲ្យខ្ញុំអាចស្នើ សុំបច្ចេកវិជ្ជាជំនួយពីនិយោជក?

គឺមានច្បាប់មួយចំនួន ដែលតម្រូវឲ្យនិយោជកត្រូវសម្រួល និងផ្ដល់ បច្ចេកវិជ្ជាជំនួយ ដល់និយោជិកទៅតាមការសម្រួលដែលមានភាពសមរម្យ ហើយច្បាប់ទាំងនោះមានដូចជាក្រមជនពិការអាមេរិកាំង (ADA, Americans with Disabilities Act) វគ្គទី 504 នៃក្រមស្តានីតិសម្បទា (Rehabilitation Act) និងច្បាប់រដ្ឋកាលីហ្វ័រនីញ៉ា (California Laws) ។

សម្រាប់ខ្លឹមសារកាន់តែលំអិត ស្តីអំពីក្រមជនពិការអាមេរិកាំង និងច្បាប់ ផ្សេងៗទៀតដែលការពារជនពិការ នៅកន្លែងការងារ សូមអានឯកសារ

បោះពុម្ពផ្សាយរបស់អង្គការ Disability Rights California *ស្តីអំពីសិទ្ធិការងារក្រោមក្រមជនពិការអាមេរិក (Employment Rights under the Americans with Disabilities Act)* ដែលមាននៅឯ ៖
http://www.disabilityrightsca.org/pubs/PublicationsEmployment.htm ។

## 3. ខ្ញុំជាជនពិការដែលលក្ខណៈសម្បត្តិទទួលបានជំនួយបច្ចេកវិជ្ជាក្រោមច្បាប់ជនពិការអាមេរិក ។ ខ្ញុំត្រូវការបច្ចេកវិជ្ជាជំនួយ សម្រាប់បំពេញការងាររបស់ខ្ញុំ ។ តើខ្ញុំអាចស្នើសុំបច្ចេកវិជ្ជាជំនួយពីនិយោជករបស់ខ្ញុំបានទេ?

អាច ។ ច្បាប់ជនពិការអាមេរិក ចែងថា វិធីមួយក្នុងចំណោមវិធីទាំងឡាយដែលនិយោជកអាចផ្តល់ភាពសម្រួលសមរម្យចំពោះអ្នក គឺការផ្តល់ឧបករណ៍ថ្មី ឬកែសម្រួលឧបករណ៍ការិយាល័យដែលមានស្រាប់ ឬបច្ចេកវិជ្ជាជំនួយ ដើម្បីអាចបំពេញភារកិច្ចសំខាន់ៗ (មុខងារស្នូល) នៃការងាររបស់អ្នក ។ 29 ក្រមនៃបទបញ្ញត្តិសហព័ន្ធ (C.F.R., Code of Federal Regulations) វគ្គទី 1630.2(o)(2)(ii) ។ ផ្ទុយមកវិញ កិច្ចការណាដែលមិនមែនជាការងារស្នូល (កិច្ចការមិនសំខាន់) អ្នកមិនត្រូវឲ្យនិយោជកត្រូវផ្តល់ភាពសម្រួលសមរម្យចំពោះអ្នកឡើយ ។ 29 ក្រមនៃបទបញ្ញត្តិសហព័ន្ធ ។ 1630(n)(1) ។ សំណើរបស់អ្នកមិនត្រូវជាការដាក់បន្ទុកហួសវិស័យចំពោះនិយោជកឡើយ ។ 29 ក្រមនៃបទបញ្ញត្តិសហព័ន្ធ វគ្គទី 1630.2(p), 1630.15(d) ។

## 4. តើខ្ញុំអាចស្នើសុំបច្ចេកវិជ្ជាជំនួយបាននៅពេលណា?

សិទ្ធិរបស់អ្នកចំពោះបច្ចេកវិជ្ជាជំនួយ គឺមាននៅគ្រប់ដំណាក់កាលទាំងអស់នៃការងារ គឺរួមទាំងដំណាក់កាលដាក់ពាក្យសុំចូលធ្វើការ និងពេលចូលបំពេញការងារ ។ 29 C.F.R. 1630.2(o)(1) ។

## 5. តើខ្ញុំអាចស្នើសុំបច្ចេកវិជ្ជាជំនួយប្រភេទណា?

ក្រមជនពិការអាមេរិកាំង មិនមានដាក់ដែនកំណត់ចំពោះប្រភេទឧបករណ៍បច្ចេកវិជ្ជាជំនួយដែលអ្នកអាចស្នើសុំនោះទេ ។ អ្វីក៏ដោយឲ្យតែអាចជួយអ្នកបានក្នុងការបំពេញការងារ គឺអាចជាការសម្រួលដែលសមរម្យមួយ ។ វាអាចជាឧបករណ៍សាមញ្ញៗ ដូចជាម៉ាស៊ីនអង្គុលីលេខសម្រាប់ប្រើតែដៃម្ខាងសម្រាប់មនុស្សដែលអាចប្រើបានតែដៃម្ខាងសម្រាប់វាយ ឬក៏ជាម៉ាស៊ីនទំនើប

ដូចជាឧបករណ៍ពិសេសផលិតឡើងសម្រាប់ការទំនាក់ទំនង ដែលអាចជួយមនុស្ស ដែលមានពិការភាពក្នុងការនិយាយ អាចប្រើសម្រាប់ទំនាក់ទំនង ។

ដើម្បីផ្តល់ឲ្យអ្នកនូវគំនិត អំពីប្រភេទផ្សេងៗនៃ ឧបករណ៍បច្ចេកវិជ្ជាដែលនិយោជកត្រូវផ្តល់ដល់និយោជិកពិការ យោងតាមច្បាប់ជនពិការអាមេរិកាំង សូមមើលតារាងឧទាហរណ៍អំពីឧបករណ៍ ដែលស្នងការឱកាសការងារស្មើភាព (EEOC, Employment Opportunities Commission) បាននិយាយថាគឺជាការសម្រួលសមរម្យ នៅក្នុង *ក្បួនខ្នាតបច្ចេកវិជ្ជាជំនួយ, កាតព្វកិច្ចការសម្រួលប្រកបដោយភាពសមរម្យ (Technical Assistance Manual, The Reasonable Accommodation Obligation) វគ្គទី III, 3.10, 6* ។ (https://askjan.org/links/ADAtam1.html):

- ឧបករណ៍ទូរគមនាគមន៍សម្រាប់មនុស្សថ្លង់ (TDDs, Telecommunication Devices for the Deaf) គឺអាចជួយដល់មនុស្សដែលមានពិការភាពក្នុងការស្តាប់ និង/ឬការនិយាយអាចទំនាក់ទំនងបានតាមទូរស័ព្ទ ។
- ទូរស័ព្ទបំពងសម្លេង គឺមានសារៈប្រយោជន៍សម្រាប់មនុស្សពិបាកស្តាប់ ។
- កម្មវិធីពិសេស សម្រាប់កុំព្យូទ័រជាបទដ្ឋាន និងឧបករណ៍ផ្សេងទៀត ដែលអាចពង្រីកអក្សរ ឬអាចបំលែងឯកសារ ដែលបោះពុម្ពលើក្រដាសទៅជាពាក្យនិយាយ សម្រាប់មនុស្សពិការភ្នែក និង/ឬពិបាកអាន ។
- សញ្ញាសំគាល់ពកៗនៅលើឧបករណ៍អក្សរសម្រាប់មនុស្សពិការភ្នែក ឬអក្សរផុសមានប្រយោជន៍ចំពោះមនុស្សដែលខ្សោយភ្នែក ។
- កាសស្តាប់ត្រចៀកសម្រាប់ប្រើទូរស័ព្ទ និងកុងតាក់ផ្លាស់ប្តូរតាមពន្លឺ គឺអាចប្រើសម្រាប់មនុស្សដែលមានកាយវិបល្លាស ឬពិការភាពផ្សេងៗទៀត ។
- ម៉ាស៊ីនគិតលេខមានសម្លេងនិយាយ អាចប្រើបានសម្រាប់ មនុស្សពិការភ្នែក ឬពិការភាពការអាន ។ ទូរស័ព្ទដែលអាចបើកឲ្យឮសម្លេងចេញក្រៅ អាចមានប្រសិទ្ធិភាពសម្រាប់មនុស្សដែលកំបុតអវៈយវៈ ឬពិការភាពផ្សេងទៀតដែលមិនអាចធ្វើចលនារំកិលបាន ។ បញ្ជីខាងក្រោម បង្ហាញឧទាហរណ៍បន្ថែមចំពោះ បច្ចេកវិជ្ជាជំនួយ និងតម្លៃរបស់វា ៖
- ឧបករណ៍កំណត់ម៉ោងដែលមានភ្លើងជាសញ្ញាបង្ហាញ គឺអាចជួយគ្រូពេទ្យដែលជាមនុស្សថ្លង់ ក្នុងការធ្វើពិសោធន៍ – តម្លៃ $27.00 ។
- លេខាដែលមិនអាចប្រើដៃបានមួយរយភាគរយ អាចយកឧបករណ៍ “តុ ឬថាសដាក់លើតុ សម្រាប់ដាក់ឯកសារ” (“lazy susan”)

ដែលអាចជួយបានក្នុងការចាប់យកសម្ភារៈទាំងអស់ដែលត្រូវការសម្រាប់ការងាររបស់គាត់ – តម្លៃ $85.00 ។

– អ្នកសំអាតទីធ្លា ដែលដៃម្ខាងមិនអាចប្រើបានល្អ អាចប្រើឧបករណ៍បន្លាយដៃ សម្រាប់ប្រើជាប្រដាប់ប្រមូលសំរាម ។ របស់នេះអាចជួយគាត់ក្នុងការចាប់ដងបន្លាយរបស់ឧបករណ៍សំអាតដោយប្រើដៃពិការ ហើយប្រើដៃដែលមិនពិការដើម្បីបញ្ជាឧបករណ៍ ប្រមូល – តម្លៃ $20.00 ។
– ទូរស័ព្ទបំពងសម្លេង ត្រូវបានរចនាឡើងសម្រាប់ប្រើជាមួយឧបករណ៍ជំនួយការស្តាប់ គឺអាចជួយកម្មកររោងចក្រ អាចបន្តការងារបានដើម្បីចៀសវាងការផ្ទេរចេញទៅកាន់មុខងារដែលទទួលបានប្រាក់ខែទាប – តម្លៃt $24.00 ។
– បុគ្គលិកទទួលភ្ញៀវជាជនពិការភ្នែកអាចទទួលបានឧបករណ៍ស្ទង់ពន្លឺសម្រាប់ប្រាប់សញ្ញា  ដែលអាចអនុញ្ញាតឲ្យបុគ្គលិកបែបនេះ កំណត់បានថាតើទូរស័ព្ទខ្សែមួយណារោទ៍ ខ្សែមួយណាកំពុងរង់ចាំ ឬខ្សែមួយណាកំពុងជាប់រវល់ ។ ឧបករណ៍ស្ទង់ពន្លឺសម្រាប់ប្រាប់សញ្ញា ឲ្យសញ្ញាជាសម្លេងនៅពេលតម្រង់វាទៅរកប្រភពដែលមានពន្លឺ – តម្លៃ $50.00 ទៅ $100.00 ។
– មនុស្សដែលប្រើដៃបានតែម្ខាង ដែលធ្វើការផ្នែកសេវាកម្មម្ហូបអាហារអាចធ្វើកិច្ចការបានគ្រប់យ៉ាង លើកលែងតែការបើកកំប៉ុង ។ បុគ្គលិកក្នុងមុខតំណែងនេះ អាចទទួលបានប្រដាប់គាស់កំប៉ុងដោយប្រើតែដៃម្ខាង – តម្លៃ $35.00 ។
– ការទិញប្រដាប់សំអាតកម្រាលឥដ្ឋដែលមានទម្ងន់ស្រាល និងអំបោសមានទំហំតូច អាចជួយនិយោជិកដែលមានពិការភាពដោយសារជម្ងឺខ្សោយបញ្ញា (Down syndrome) និងជម្ងឺបេះដូងដើរខុសប្រក្រតីពីកំណើត អាចធ្វើការបានដោយ មានបញ្ហាជម្ងឺធ្វើទុកតិចតួចបំផុត – តម្លៃក្រោម $40 ។
– អ្នកបើកឡានធំ កើតជម្ងឺស្ពឹកម្រាមដៃ ដែលធ្វើឲ្យគាត់ពិបាកកម្រើកកដៃ ហើយធ្វើឲ្យមានភាពលំបាកខ្លាំងក្នុងពេលអាកាសធាតុត្រជាក់ខ្លាំង។ ព្រួលពិសេសសម្រាប់អបកដៃប្រើជាមួយស្រោមដៃ ដែលបានរចនាឡើងសម្រាប់អ្នកមុជទឹក អាចជួយគាត់ឲ្យបើកឡានបានទោះបីស្ថិតក្រោមអាកាសធាតុត្រជាក់ខ្លាំងយ៉ាងណាក៏ដោយ – តម្លៃ $55.00 ។

- កាសទូរស័ព្ទ អាចជួយដល់អ្នកលក់ធានារ៉ាប់រងដែលមានកាយវប្បលាស អាចសរសេរបានក្នុងពេលកំពុងនិយាយជាមួយអតិថិជន – តម្លៃជួលឧបករណ៍គឺ $6.00 ក្នុងមួយខែ ។
- ទម្រង់ក្រដាសរឹងធម្មតា ដែលហៅថា "ឧបករណ៍សម្រាប់បត់តវ៉ាន់" ("jig") អាចជួយមនុស្សដែលមានពិការភាពខួរក្បាល បត់ខោខូវប៊យបានយ៉ាងល្អ ក្នុងមុខងារជាស្មៀនឃ្លាំងចំពោះហាងលក់រាយ – តម្លៃ $0 ។

## 6. តើខ្ញុំត្រូវធ្វើអ្វី ទើបអាចទទួលបានឧបករណ៍ជំនួយត្រឹមត្រូវសម្រាប់ការងារខ្ញុំ?

ដំណើរការគឺចាប់ផ្តើមពីការអនុញ្ញាតឲ្យនិយោជករបស់អ្នកបានដឹងថាអ្នកមានពិការភាពក្នុងខ្លួន ហើយអ្នកត្រូវការបច្ចេកវិជ្ជាជំនួយសម្រាប់ធ្វើកិច្ចការរបស់អ្នក ។ តមកទៀត អ្នកត្រូវស្នើសុំការប្រជុំ ដើម្បីពិភាក្សាអំពីតម្រូវការជាក់លាក់របស់អ្នក ។ បើអ្នក ឬនិយោជករបស់អ្នកដឹងច្បាស់អំពីបច្ចេកវិជ្ជាជំនួយ អ្នកអាចព្រមព្រៀងជាមួយថៅកែអំពីអ្វីដែលត្រូវនឹងតម្រូវការរបស់អ្នកបាន ។ អ្នកត្រូវកត់ត្រាទុកនូវខ្លឹមសារចំពោះការពិភាក្សា និងលក្ខ័ណ្ឌនៃកិច្ចព្រមព្រៀង ។

និយោជករបស់អ្នក មិនចាំបាច់ត្រូវតែទិញឧបករណ៍ជំនួយដែលមានតម្លៃថ្លៃ ឬឧបករណ៍ដែលទើបផលិតចេញថ្មីៗឡើយ ។ តាមពិតទៅ និយោជករបស់អ្នក មិនចាំបាច់ត្រូវតែទិញឧបករណ៍ជំនួយឲ្យអ្នកឡើយ បើតម្រូវការរបស់អ្នកអាចដោះស្រាយបានដោយវិធីផ្សេង ។ និយោជករបស់អ្នក មិនអាចសំអាងលើតម្លៃឧបករណ៍ជំនួយ យកមកធ្វើជាមូលហេតុមិនជួយអ្នកទេ លើកលែងតែថាវាមិនមានវិធីណាមួយផ្សេងទៀតដើម្បីដោះស្រាយបាន ហើយនិយោជកអាចបញ្ជាក់ថា ឧបករណ៍ជំនួយនោះវាមានតម្លៃថ្លៃហួសពីអ្វីដែលខ្លួនអាចដោះស្រាយបាន ។ ផ្ទុយមកវិញ នៅពេលដែលជម្រើសមួយត្រូវបានបដិសេធចោល និយោជកត្រូវពិចារណាចំពោះជម្រើសផ្សេងទៀតដែលសមរម្យ ។ ឧទាហរណ៍ ប្រសិនបើមិនមានជម្រើសផ្សេងទៀតដែលសមរម្យ ដោយសារឧបករណ៍ជំនួយមានតម្លៃថ្លៃពេក និយោជកត្រូវផ្តល់ឱកាសឲ្យអ្នក រកឧបករណ៍ជំនួយដោយខ្លួនឯង ។

## 7. តើនិយោជកអាចតម្រូវឲ្យខ្ញុំសុំលិខិតពីគ្រូពេទ្យ ដែលបញ្ជាក់ថា តើខ្ញុំត្រូវការឧបករណ៍បច្ចេកវិជ្ជាជំនួយប្រភេទណាដែរឬទេ?

ទេ ។ ចំពោះហេតុការណ៍ភាគច្រើន គ្រូពេទ្យមិនមានចំណេះដឹងគ្រប់គ្រាន់ ដើម្បីណែនាំអំពីឧបករណ៍បច្ចេកវិជ្ជាជំនួយឡើយ ។ បើអ្នកដឹងមិនច្បាស់

ឬអ្នកមិនអាចយល់ព្រមចំពោះឧបករណ៍ជំនួយទេ និយោជករបស់អ្នកត្រូវស្នើសុំធ្វើការវាយតម្លៃ ដែលធ្វើឡើងដោយអ្នកវាយតម្លៃដែលអាចផ្តល់អនុសាសន៍បានចំពោះជម្រើសដែលមានប្រសិទ្ធិភាព ។ សូមអានឧបសម្ព័ន្ធអំពី 29 C.F.R. វគ្គទី 1630.9 ក្រោម *ដំណើរការអំពីការកំណត់ការសម្រួលដែលមានហេតុផលសមរម្យ (Process of Determining the Appropriate Reasonable Accommodation) ។*

គឺមានអ្នកជំនាញឯកទេស ដែលអាចធ្វើការវាយតម្លៃបានអំពីតម្រូវការចំពោះឧបករណ៍បច្ចេកវិជ្ជាជំនួយ ។ អ្នកជំនាញឯកទេសភាគច្រើន ជាអ្នកធ្វើការក្នុងផ្នែកស្តានីតិសម្បទាប្រចាំមន្ទីរពេទ្យនានា ។ រីឯអ្នកជំនាញឯកទេសផ្សេងទៀត គឺជាអ្នកធ្វើការនៅតាមអង្គការជនពិការ ។ក៏មានអ្នកលក់ឧបករណ៍ប្រភេទនេះ ដែលជាអ្នកធ្វើការវាយតម្លៃអំពីតម្រូវការចំពោះឧបករណ៍ជំនួយបច្ចេកវិជ្ជាផងដែរ ។ អ្នកប្រឹក្សាយោបល់ ប្រចាំនាយកដ្ឋានស្តានីតិសម្បទា (DOR, Department of Rehabilitation) អ្នកឯកទេសប្រចាំមជ្ឈមណ្ឌលការរស់នៅដោយឯករាជ្យ ឬអ្នកចាត់ចែងសំណុំរឿងប្រចាំមជ្ឈមណ្ឌលប្រចាំតំបន់ (regional center) អាចប្រាប់អ្នកបានពីកន្លែងដែលអ្នកត្រូវទៅ ។ ការវាយតម្លៃ ត្រូវអាចប្រាប់អ្នកបានថាតើបច្ចេកវិជ្ជាជំនួយប្រភេទណាដែលអ្នកត្រូវការ ។

## 8. តើនិយោជកអាចទទួលបានអ្វីពីគ្រូពេទ្យរបស់ខ្ញុំ?

និយោជករបស់អ្នក អាចត្រឹមតែមានសិទ្ធិដឹងបានអំពីស្ថានភាពដែលអ្នកជួប្រទះបណ្តាលពីពិការភាពរាងកាយ និងខួរក្បាលរបស់អ្នក តែប៉ុណ្ណោះ ។ កំណត់ហេតុរបស់គ្រូពេទ្យ គួរមានរៀបរាប់អំពីពិការភាព និងមូលហេតុដែលពិការភាពប៉ះពាល់ចំពោះសមត្ថភាពរបស់អ្នកក្នុងការបំពេញមុខងារសំខាន់ៗនៃកិច្ចការរបស់អ្នក ។ គ្រូពេទ្យរបស់អ្នក មិនត្រូវផ្តល់ព័ត៌មានផ្សេងទៀតស្តីអំពីវេជ្ជសាស្ត្រ និងចិត្តសាស្ត្រ របស់អ្នកដែលមិនពាក់ព័ន្ធនឹងបរិបទឡើយ ។ បើអ្នកអាចផ្តល់ព័ត៌មាននេះតាមរយៈឯកសារផ្សេងដែលអាចយកជាការបាន គឺមិនចាំបាច់ឲ្យមានគ្រូពេទ្យរបស់អ្នកចូលមកពាក់ព័ន្ធឡើយ ។

## 9. តើខ្ញុំអាចធ្វើអ្វីបាន ប្រសិនបើនិយោជករបស់ខ្ញុំបដិសេធមិនផ្តល់ឧបករណ៍ជំនួយដល់ខ្ញុំ?

អ្នកអាចដាក់ពាក្យតវ៉ាជាមួយភ្នាក់ងារណាមួយ ឬក៏ដាក់ពាក្យបណ្តឹងទៅកាន់តុលាការ ។ ចំពោះស្ថានភាពភាគច្រើន អ្នកត្រូវដាក់ពាក្យតវ៉ាជាមុនសិន

ទើបអាចប្តឹងទៅតុលាការនាពេលក្រោយ ។ សម្រាប់ព័ត៌មានបន្ថែម សូមអានឯកសារបោះពុម្ពផ្សាយរបស់យើងខ្ញុំដែលមានចំណងជើងថា *សិទ្ធិការងារក្រោមក្រមជនពិការអាមេរិកាំង (Employment Rights under the Americans with Disabilities Act) មាននៅឯ ៖* [http://www.disabilityrightsca.org/pubs/PublicationsEmployment.htm](http://www.disabilityrightsca.org/pubs/PublicationsEmployment.htm) ។

## 10. តើមានប្រភពផ្តល់ថវិកាជំនួយ ដែលអាចជួយខ្ញុំបានក្នុងការទទួលបានឧបករណ៍ជំនួយដោយខ្លួនឯងបានទេ?

មាន ។ ផែនការដើម្បីសម្រេចបានការជ្រោមជ្រែងខ្លួនឯង (PASS, Plan to Achieve Self-Support) អាចអនុញ្ញាតឲ្យអ្នកទទួលបានអត្ថប្រយោជន៍សន្តិសុខសង្គម (Social Security) ដើម្បីសន្សំប្រាក់ថ្លៃទិញឧបករណ៍ជំនួយ ។ នាយកដ្ឋានស្តានីតិសម្បទា ក៏អាចផ្តល់ប្រាក់ដើម្បីទិញឧបករណ៍ជំនួយបានដែរ ។ សម្រាប់ព័ត៌មានបន្ថែម សូមអានអត្ថបទបោះពុម្ពផ្សាយរបស់យើងខ្ញុំចំពោះប្រធានបទទាំងនេះ ៖ [http://www.disabilityrightsca.org/pubs/PublicationsAssistiveTechnology.htm](http://www.disabilityrightsca.org/pubs/PublicationsAssistiveTechnology.htm) និង [http://www.disabilityrightsca.org/pubs/PublicationsClientAssistanceProgram.htm](http://www.disabilityrightsca.org/pubs/PublicationsClientAssistanceProgram.htm)

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្សេងៗគ្នា។ ដើម្បីបើកមើលបញ្ជីម្ចាស់ជំនួយទាំងអស់ សូមចូលទៅកាន់* [http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html](http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html) ។